# មេរៀនទី៧៖ សកម្មភាពដែលអាចធ្វើជាបុគ្គល និងសមូហភាព

## ACTIONS THAT CAN BE TAKEN INDIVIDUALLY AND COLLECTIVELY

**ខ្លឹមសារនៃមេរៀន**

វត្ថុបំណងនៃមេរៀន

សំណួរបំផុស

១. សេចក្ដីផ្ដើម

២. និយមន័យ

- ក. បុគ្គលភាព
- ខ. សមូហភាព
- គ. សកម្មភាពបុគ្គល និងសកម្មភាពសមូហភាព
- ឃ. ការងារបុគ្គល និងការងារក្រុម

៣. គុណសម្បត្តិ និងគុណវិបត្តិនៃការរៀនម្នាក់ឯង និងការរៀនជាក្រុម

- ក. គុណសម្បត្តិនៃការសិក្សាតែម្នាក់ឯង ឬជាបុគ្គល
- ខ. គុណវិបត្តិនៃការសិក្សាតែម្នាក់ឯង ឬជាបុគ្គល
- គ. គុណសម្បត្តិនៃការសិក្សាជាក្រុម ឬជាសមូហភាព
- ឃ. គុណវិបត្តិនៃការសិក្សាជាក្រុម ឬជាសមូហភាព

៤. លក្ខណៈខុសគ្នាចំពោះការធ្វើការតែម្នាក់-ជាបុគ្គល និងជាក្រុម-ជាសមូហភាព

៥. ការបញ្ជ្រាបសកម្មភាពបុគ្គល និងសមូហភាពនៅក្នុងមេរៀន និងក្នុងសង្គម

៦. សេចក្ដីសន្និដ្ឋាន

| សម្បទា | ការបរិយាយ |
| --- | --- |
| **វិជ្ជាសម្បទា** | មានការយល់ដឹងកាន់តែស៊ីជម្រៅទៅលើអត្ថន័យ និងខ្លឹមសារនៃមេរៀន ដូចជាភាពខុសគ្នារវាងសកម្មភាពបុគ្គល សកម្មភាពសមូហភាព និងសកម្មភាពដែលអាចធ្វើជាលក្ខណៈបុគ្គល និងលក្ខណៈសមូហភាពបាន។ |
| **បំណិនសម្បទា** | អាចធ្វើការវិភាគ ពន្យល់ និងបកស្រាយបានកាន់តែស៊ីជម្រៅទៅលើអត្ថន័យ និងខ្លឹមសារនៃមេរៀនដូចជាភាពខុសគ្នារវាងសកម្មភាពបុគ្គល សកម្មភាពសមូហភាព និងសកម្មភាពដែលអាចធ្វើជាលក្ខណៈបុគ្គល និងជាលក្ខណៈសមូហភាពបាន។ |
| **ចរិយាសម្បទា** | លើកទឹកចិត្តនិងជំរុញស្មារតីឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការធ្វើសកម្មភាពជាលក្ខ ណៈបុគ្គល និងសមូហភាព។ |

# សំណួរពិភាក្សា

1. តើសកម្មភាពបុគ្គលគឺជាអ្វី? ចូរលើកឡើងពីគុណសម្បត្តិ និងគុណវិត្តិនៃសកម្មភាពបុគ្គល។
2. តើសកម្មភាពសមូហភាពគឺជាអ្វី? ចូរលើកឡើងពីគុណសម្បត្តិ និងគុណវិត្តិនៃសកម្មភាពសមូហភាព។
3. ចូរលើកឡើងពីសារៈសំខាន់នៃសកម្មភាពបុគ្គល និងសកម្មភាពសមូហភាពចំពោះការសិក្សា។
4. តើយើងត្រូវធ្វើដូចម្តេចដើម្បីបញ្ជ្រាបសកម្មភាពបុគ្គល និងសកម្មភាពសមូហភាពទៅក្នុងមេរៀន និងទៅក្នុងសង្គម?

1. Participants are divided into 17 groups. Each group consists of 3 (1 management team, and 2 teacher trainers).
2. Spend about 15 minutes to discuss and answer the above-mentioned questions.
3. They, then, present their answers to the class.
4. NIE trainer leads and facilitates these discussions.

**Video clip**

https://youtu.be/CW7aWKXB5J4 ( 3 )

https://youtu.be/M199uez5LvA ( 4 )

https://youtu.be/6fbE52YDEjU ( individual and collective 1 )

https://youtu.be/YuOJjUUMDbQ ( Solidarity 2 )

## ១. សេចក្តីផ្តើម



- ពលរដ្ឋប្រៀបបានដូចជាកោសិកាមួយយ៉ាងសំខាន់ ក្នុងការបំពេញនូវលក្ខណៈសម្បត្តិសម្រាប់ប្រទេសជាតិ ហើយវាក៏ជាផ្នែកមួយដែលធ្វើឱ្យមានការរីកចម្រើន ការអភិវឌ្ឍ និងភាពសុខដុមរមនាផងដែរ។ ពលរដ្ឋម្នាក់ៗមានភារកិច្ច និងកាតព្វកិច្ចដូចគ្នានិងស្មើគ្នា ក្នុងការចូលរួមគ្រប់សកម្មភាព និងគ្រប់រូបភាព។
- ការបញ្ជ្រាបនូវចំណេះដឹងភាពជាពលរដ្ឋសកល ទាក់ទងនឹងសកម្មភាពបុគ្គល និងសមូហភាព ព្រមទាំងអាចញ៉ាំងឱ្យសិស្សានុសិស្សមានស្មារតីចូលរួមគិត និងធ្វើកិច្ចការគាំពារ ការពារ និងថែរក្សាវឌ្ឍភាព និងភាពសុខសាន្តនៃសង្គមយើងទាំងមូល។ ចំណេះដឹងទាំងនោះក៏មានសារៈសំខាន់ក្នុងការបណ្តុះស្មារតីបុគ្គលគ្រប់វ័យនៃជាតិសាសន៍នោះឱ្យស្គាល់នូវតម្លៃ និងភារកិច្ចខ្លួនក្នុងកិច្ចការសង្គម ដែលជាទុនដ៏ចាំបាច់សម្រាប់ការអភិវឌ្ឍនៃសង្គមដ៏មាន និរន្តភាព និងចីរភាព។
- ចំពោះការសិក្សាវិញ មនុស្សយើងមានវិធីសាស្ត្រខុសៗពីគ្នា ដោយអ្នកខ្លះចូលចិត្តរៀនតែម្នាក់ឯង ចំណែកអ្នកខ្លះទៀតចូលចិត្តរៀនជាក្រុម។ ទោះជាយ៉ាងណាក៏ដោយ មិនថាអ្នកជ្រើសរើស ឬចូលចិត្តរៀនតាមរយៈវិធីសាស្ត្រណាក៏ដោយសុទ្ធតែមានគុណសម្បត្តិ និងគុណវិបត្តិដូចគ្នាទាំងអស់។ នៅក្នុងមេរៀននេះ យើងនឹងសិក្សាពីសកម្មភាពបុគ្គល និងសកម្មភាពសមូហភាព។ ការអភិវឌ្ឍសង្គមផ្តើមចេញពីការប្រមូលផ្តុំទាំងសកម្មភាពបុគ្គល និងសកម្មភាពសមូហភាព។ បើគ្មានសកម្មភាពបុគ្គល និងសមូហភាពទេ ក៏មិនមានចលនាសង្គមដែរ។ (Cases-Cortes et al., 2008)

## ២. និយមន័យ

| | |
|---|---|
| ក. បុគ្គលភាព | • គឺជាមនុស្សដែលមានលក្ខណៈខុសពីអ្នកដទៃ និងជាអ្នកដែលមានគោលដៅ ឬតម្រូវការផ្ទាល់ខ្លួន និងជាអ្នកដែលមានសិទ្ធិ និងទំនួលខុសត្រូវដោយឡែកពីមនុស្សដទៃ ពីក្រុម ឬពីសមូហភាព។ |
| ខ. សមូហភាព | • គឺជាក្រុមមួយនៃអង្គភាពដែលត្រូវសហការ និងធ្វើការរួមគ្នា ដើម្បីសម្រេចបាននូវវត្ថុបំណងរួម។ |
| គ. សកម្មភាពបុគ្គល និង សកម្មភាពសមូហភាព | • សកម្មភាពបុគ្គលសំដៅលើសកម្មភាពទាំងឡាយណាដែលរៀបចំ ឬធ្វើឡើងដោយបុគ្គលណាម្នាក់ ហើយការធ្វើសកម្មភាពនោះផ្អែកលើការសម្រេចចិត្តរបស់បុគ្គលនោះឯងផ្ទាល់។ ចំណែកឯសកម្មភាពសមូហភាព សំដៅលើសកម្មភាពទាំងឡាយណាដែលរៀបចំ ឬធ្វើឡើងដោយសមូហភាព ឬក្រុមណាមួយ ហើយការធ្វើសកម្មភាពនោះផ្អែកលើការសម្រេចចិត្តរបស់សមូហភាព។ |
| ឃ. ការងារបុគ្គល និង ការងារក្រុម | • ការងារបុគ្គលគឺការងារទាំងឡាយណាដែលរៀបចំ ឬធ្វើឡើងដោយបុគ្គលណាម្នាក់ ហើយការធ្វើការងារនោះផ្អែកលើការសម្រេចចិត្តរបស់បុគ្គលនោះឯងផ្ទាល់។ ការងារក្រុមគឺជាការងារដែលបុគ្គលពីរនាក់ ឬច្រើននាក់ សហការគ្នាធ្វើ ដើម្បីឱ្យបានសម្រេចតាមគោលដៅដែលចង់បាន។ |

# ៣. គុណសម្បត្តិ និងគុណវិបត្តិនៃការរៀនម្នាក់ឯង និងការរៀនជាក្រុម

| ក. គុណសម្បត្តិនៃការសិក្សាតែម្នាក់ឯង ឬជាបុគ្គល | ខ. គុណវិបត្តិនៃការសិក្សាតែម្នាក់ឯង ឬជាបុគ្គល |
|---|---|
| 1. មានភាពឯករាជ្យ<br>2. មិនខាតពេលវេលា<br>3. អាចផ្តោតអារម្មណ៍បានល្អ<br>4. មានទំនុកចិត្តក្នុងការបញ្ចេញនូវសមត្ថភាពផ្ទាល់ខ្លួន<br>5. មានការបង្កើតនូវស្នាដៃរបស់ខ្លួន ឬជាចំណេះដឹងដែលមាន<br>6. អាចទទួលបាននូវចំណេះដឹងនិងបទពិសោធន៍ថ្មីៗពីការស្រាវជ្រាវ<br>7. មានភាពងាយស្រួលក្នុងការសម្រេច ឬវិនិច្ឆ័យធ្វើអ្វីមួយ<br>8. អាចធ្វើការគិតពិចារណាលើកិច្ចការអ្វីមួយបានដោយមិនមានការកំណត់ពេលវេលា | 1. គ្មានអ្នកពិភាក្សា<br>2. មានការចំណាយពេលវេលាច្រើនក្នុងការសិក្សាស្រាវជ្រាវ<br>3. ស្ត្រេស (អាចមានភាពស្ត្រេស តានតឹងក្នុងអារម្មណ៍)<br>4. មិនមានការកែតម្រូវលើចំណុចដែលខ្វះខាត<br>5. អាចមានការយឺតយ៉ាវក្នុងការសម្រេចការងាររបស់ខ្លួន<br>6. ផលដែលទទួលបានមិនសូវមានលក្ខណៈគ្រប់គ្រាន់<br>7. មានភាពនឿយហត់ច្រើនក្នុងការធ្វើកិច្ចការមួយ<br>8. មានការចំណាយថវិកាច្រើនក្នុងការធ្វើជាឯកសារ<br>9. មិនមានគំនិតទូលំទូលាយក្នុងការបំពេញកិច្ចការ |

## គ. គុណសម្បត្តិនៃការសិក្សាជាក្រុម ឬជាសមូហភាព

**ធ្វើឱ្យសមាជិកក្នុងក្រុម៖**

1. មានឱកាសក្នុងការផ្លាស់ប្តូរបទពិសោធន៍ និងសហការណ៍គ្នា
2. មានភាពស្និទស្នាលនឹងគ្នា
3. មានការចូលរួមយ៉ាងសកម្ម ជំរុញឱ្យអ្នកអសកម្មចូលរួមពិភាក្សា ដោះស្រាយ និងធ្វើឱ្យពួកគេទទួលបាននូវចំណេះដឹងផ្សេងៗ
4. មានការចែករំលែកគំនិត និងចំណេះដឹងដែលទាក់ទងនឹងជំនាញផ្សេងៗ ហើយការរៀនជាក្រុមបែបនេះ ជួយឱ្យអ្នកមានការអភិវឌ្ឍសមត្ថភាពខ្លាំង
5. ប្រសិនបើយើងរៀនមិនសូវចេះ យើងអាចបង្កើតជាក្រុមដើម្បីឱ្យសិស្សដែលពូកែនៅក្នុងថ្នាក់ជួយបង្រៀន យើងព្រោះការធ្វើបែបនេះ អាចជួយឱ្យអ្នករៀនបានច្រើនជាងមុន
6. មានឱកាសសួរសំណួរយ៉ាងច្រើនទៅកាន់មិត្តភក្តិរបស់យើងដោយហេតុថា ពេលខ្លះយើងអាចនឹងមិនសូវហ៊ានសួរទៅកាន់លោកគ្រូរបស់យើង និងមានការចំណាយថវិកាតិច ដោយមានការចូលរួមចែករំលែក។

## ឃ. គុណវិបត្តិនៃការសិក្សាជាក្រុម ឬជាសមូហភាព

1. ត្រូវការកំណត់ និងជ្រើសរើសទីតាំងដើម្បីជួបជុំគ្នា
2. ត្រូវការពេលវេលាច្រើនដើម្បីធ្វើការពិភាក្សា
3. សមាជិកក្រុមខ្លះមិនសូវចូលរួមសហការណ៍ក្នុងពេលពិភាក្សា
4. ការសិក្សាជាក្រុមអាចធ្វើឱ្យសមាជិកក្នុងក្រុមមួយចំនួនមានភាពខ្ជិលច្រអូស។ ឧទាហរណ៍បើរៀនជាមួយគ្នារាល់ថ្ងៃ ពួកអ្នកដែលខ្សោយ មិនព្យាយាមធ្វើលំហាត់ដោយខ្លួនឯងនៅផ្ទះនោះទេ ប៉ុន្តែចាំមកដល់ពេលរៀនវិញទើបសួរចម្លើយពីអ្នកដទៃ





# ៤. លក្ខណៈខុសគ្នាចំពោះការធ្វើការតែម្នាក់-ជាបុគ្គល និងជាក្រុម-ជាសមូហភាព

**ក. ភាពឆាប់រហ័សនៃការងារ**

ជាបុគ្គល.......

ជាក្រុម ............





**ខ. សហការសម្រេចចិត្ត**

ជាបុគ្គល.......

ជាក្រុម ............





**គ. ការបង្កើតគំនិត**

ជាបុគ្គល.......

ជាក្រុម ............





**ឃ. ការបង្កើតសម្ព័ន្ធភា**

ជាបុគ្គល.......

ជាក្រុម ............





**ង. ការងារស្របនឹងសមត្ថភាព**

ជាបុគ្គល.......

ជាក្រុម ............





- Students work in groups.
- Discuss and answer the questions in written form.
- They, then, present their answers to the class with the NIE’s trainer facilitate.

## ៥. ការបញ្ជ្រាបសកម្មភាពបុគ្គល និងសមូហភាពនៅក្នុងមេរៀន និងក្នុងសង្គម

**កិច្ចការ និងប្រធានបទដែលគ្រូអាចបញ្ជ្រាបទៅក្នុងមេរៀនដើម្បីជំរុញឱ្យមានសកម្មភាពជាបុគ្គល ឬសមូហភាពនៅតាមកម្រិតភូមិសិក្សា៖**

**ក. ថ្នាក់មត្តេយ្យសិក្សានិងថ្នាក់អប់រំកុមារតូច៖** សកម្មភាពដែលពួកគាត់អាចធ្វើបាន (១) ការថែរក្សានិងការកែលម្អផ្ទះសម្បែងដែលពួកគេរស់នៅ និង (២) ការសម្អាតបរិស្ថានសាលារៀន ការប្រមូលផ្តុំគ្នាដើម្បីសម្អាតទីធ្លាសាលា (៣) ការកាត់បន្ថយការប្រើប្លាស្ទិក និងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត។

**ខ. ថ្នាក់បឋមសិក្សា៖** (១) ទំនាក់ទំនងរវាងបុគ្គល និងសមូហភាព (២) ចូលរួមប្រកបដោយសុខដុមរមនាក្នុងវប្បធម៌ផ្សេងៗគ្នា (៣) ចូលរួមកំណត់អត្តសញ្ញាណនៃបញ្ហាដើម្បីរកដំណោះស្រាយរួម និង (៤) ចូលរួមក្លឹមសិក្សា សកម្មភាពសិក្សា កីឡា និងពលកម្មសាលា និងសង្គម។

**គ. កម្រិតអនុវិទ្យាល័យ៖** (១) កំណត់តួនាទី និងកាតព្វកិច្ចរបស់បុគ្គល និងក្រុម ក្នុងការធ្វើសកម្មភាព (២) ការគិតទុកជាមុន និងការវិភាគលទ្ធផលនៃសកម្មភាព (៣) ការកំណត់អត្តសញ្ញាណសកម្មភាពដែលបានធ្វើឡើងដើម្បីកែលម្អសាលារៀន (៤) កំណត់អត្ថប្រយោជន៍ ឱកាស និងផលប៉ះពាល់នៃការចូលរួមរបស់ខ្លួន និង (៥) កត្តារួមចំណែកដល់ភាពជោគជ័យរបស់បុគ្គល និងសមូហភាព។

**ឃ. មធ្យមសិក្សាទុតិយភូមិ៖** (១) កត្តាដែលអាចពង្រឹង ឬកម្រិតនៃការចូលរួមធ្វើសកម្មភាពជាលក្ខណៈបុគ្គល និងសមូហភាព (២) ការជ្រើសរើសមធ្យោបាយសមស្របបំផុតសម្រាប់ទទួលបានព័ត៌មាន ការបញ្ចេញមតិនិងចាត់វិធានការ លើបញ្ហាសកលសំខាន់ៗ (ប្រសិទ្ធភាព លទ្ធផល ផលប៉ះពាល់អវិជ្ជមាន ការពិចារណាខាងសីលធម៌) (៣) គម្រោងសហការលើបញ្ហាមូលដ្ឋាន និងការព្រួយបារម្ភជាសកល ដូចជាបរិស្ថាន ការកសាងសន្តិភាព ការប្រកាន់ពូជសាសន៍។ល។

## ង. ចំពោះមុខវិជ្ជាសង្គម៖

(1) ធ្វើជាកូនល្អក្នុងគ្រួសារ សិស្សល្អក្នុងសាលា និងពលរដ្ឋល្អក្នុងសង្គម

(2) ចូលរួមក្នុងសកម្មភាពសង្គម ដូចជាការងារមនុស្សធម៌ ការគោរពច្បាប់ ការគោរពសិទ្ធិ-សេរីភាពចំពោះគ្នា និងគ្នា

(3) ធ្វើខ្លួនឱ្យទៅជាធនធានមួយល្អ ដើម្បីក្លាយទៅជាទំពាំងស្នងឬស្សីរបស់ប្រទេសជាតិ

(4) លើកស្ទួយ និងលើកតម្កើងវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ប្រពៃណី អត្តសញ្ញាណជាតិរបស់ខ្លួន ទាំងក្នុងប្រទេស ទាំងលើឆាកអន្តរជាតិ ព្រោះថាអ្វីៗទាំងអស់ត្រូវចាប់ផ្តើមចេញពីខ្លួនឯងជាមុខសិន ទើបអ្នកដទៃគេលើកតម្កើង និងឱ្យតម្លៃជាក្រោយ

(5) សាមគ្គីគ្នាជាធ្លុងមួយ ដូចពាក្យស្លោកមួយលើកឡើងថាចង្កឹះមួយអាចកាច់បាក់ តែចង្កឹះមួយបាច់មិនអាចកាច់បាក់ឡើយ

(6) លុបបំបាត់រាល់ទម្រង់ទាំងឡាយណាដែលជាសញ្ញាណនៃការរើសអើង ការប្រកាន់វណ្ណៈ និងការប្រកាន់បក្ខពួក ព្រោះថាកត្តាទាំងនេះ ជាផ្នែកមួយធ្វើឱ្យសង្គមមិនអាចរីកចម្រើនទៅមុខបាន

(7) ជៀសវាងការប្រព្រឹត្តអំពើអបាយមុខ និងការប្រព្រឹត្តបទល្មើសផ្សេងៗដូចជា ការជួញដូរនិងសេពគ្រឿងញៀន ការលួច ការឆក់ ការប្លន់ ល្បែងស៊ីសងគ្រប់ប្រភេទ

(8) ត្រូវបដិសេធ និងមិនត្រូវចូលរួមជាដាច់ខាតនូវរាល់អំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ក្នុងចេតនាបង្កឱ្យមានវឹកវរដល់សង្គមជាតិ។

# POST TEST

1. តើសកម្មភាពបុគ្គល និងសកម្មភាពសមូហភាព គឺជាអ្វី? ចូរលើកឡើងពីគុណសម្បត្តិ និងគុណវិបត្តិនៃសកម្មភាពនីមួយៗ។
2. ចូរលើកឡើងពីសារៈសំខាន់នៃសកម្មភាពបុគ្គល និងសកម្មភាពសមូហភាពចំពោះការសិក្សា។
3. តើយើងត្រូវធ្វើដូចម្តេចដើម្បីបញ្ជ្រាបសកម្មភាពបុគ្គល និងសកម្មភាពសមូហភាពទៅក្នុងមេរៀន?

# ៦. សេចក្តីសន្និដ្ឋាន

- ការធ្វើខ្លួនឱ្យទៅជាពលរដ្ឋល្អ ពោលគឺជាពលរដ្ឋដែលចេះធ្វើការងារជាបុគ្គល និងសមូហភាព គឺជារឿងមួយដ៏ប្រពៃសម្រាប់ប្រទេសជាតិ ព្រោះថាកាលណាប្រទេសជាតិមួយដែលសម្បូរទៅដោយពលរដ្ឋល្អ មានន័យថាប្រទេសជាតិនោះនឹងមានភាពរឹងមាំ ភាពខ្លាំងនិងការអភិវឌ្ឍលើវិស័យសេដ្ឋកិច្ច និងមានធនធានមនុស្សចម្រុះ។ ប្រទេសជាតិនានាក្នុងពិភពលោក តែងតែត្រូវការជានិច្ចនូវកោសិកាមួយដែលគេហៅថាពលរដ្ឋល្អក្នុងប្រទេសរបស់ខ្លួន ព្រោះថានៅពេលណាដែលសម្បូរទៅដោយពលរដ្ឋល្អ នៅពេលនោះ អ្វីៗដែលល្អ ដែលសម្បូរបែប នឹងកើតមានឡើងក្នុងប្រទេសនោះជាក់ជាមិនខាន។
- ក្រោយពីបានធ្វើការសិក្សាវែកញែកពីគុណសម្បត្តិ និងគុណវិបត្តិនៃសកម្មភាពជាក្រុម និងជាលក្ខណៈបុគ្គល យើងបានឃើញថាវិធីទាំងពីរនេះសុទ្ធតែមានប្រសិទ្ធភាពដូចៗគ្នា និងមានចំណុចវិជ្ជមាន និងអវិជ្ជមានដូចគ្នា ដោយគ្រាន់តែថាក្នុងករណីខ្លះ យើងត្រូវពិនិត្យមើលលើស្ថានភាពជាក់ស្តែងនៃកិច្ចការនោះថា តើវាមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្កើតក្រុមពិភាក្សាឬក៏អាចធ្វើជាលក្ខណៈបុគ្គលបាន។ សរុបសេចក្តីមក មិនថាការពិភាក្សាជាលក្ខណៈបុគ្គលឬជាក្រុម ថាមួយណាល្អប្រសើរជាងមួយណានោះទេ គឺវាតែងតែមានការប្រស្រ័យទាក់ទងគ្នាទៅវិញទៅមកដោយផ្អែកលើស្ថានភាព លក្ខណៈនៃកិច្ចការមួយនោះ។